# ចតុរង្គសន្និបាត



*ចតុរង្គសន្និបាត ការប្រជុំ ឬ ការជួបជុំប្រកបដោយអង្គ ៤ របស់ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ ដើម្បីទ្រង់សំដែងនូវឱវាទប្បាតិមោក្ខ ។*

## ១. ចតុរង្គសន្និបាតរបស់ព្រះសម្មាសម្ពុទ្ធសមណគោតម

**១- មាឃនក្ខត្តេន យុត្តោ បុណ្ណមុបោសថទិវសោ** *ថ្ងៃឧបោសថព្រះចន្ទពេញវង់ ប្រកបដោយផ្កាយប្រចាំខែមាឃ: គឺថ្ងៃ ១៥ កើតមាឃ: ។*

**២- កេនចិ អនាមន្តិតានិ ហុត្វា អត្តនោយេវ ធម្មតាយ សន្និបតិតានិ អឌ្ឍតេឡសានិ ភិក្ខុសតានិ** *ភិក្ខុ ១២៥០ រូប ឥតមាននរណានិមន្តឡើយ ស្រាប់តែមកប្រជុំគ្នាតាមធម្មតារបស់ខ្លួន ។*

**៣- តេសុ ឯកោបិ បុថុជ្ជនោ វា សោតាបន្នសកទាគាមិអនាគាមិសុក្ខវិបស្សកអរហន្តេសុ វា អញ្ញតរោ នត្ថិ សព្វេ ឆឡភិញ្ញាវ** *ភិក្ខុអម្បាលនោះជាបុថុជ្ជន ឬសោតាបន្ន សកទាគាមី អនាគាមី ឬព្រះអរហន្តសុក្ខវិបស្សកៈ សូម្បីតែ ១ រូបក៏មិនមាន សុទ្ធតែជាព្រះអរហន្តបានអភិញ្ញាណ ៦ គ្រប់រូប ។*

**៤- ឯកោបិ ចេត្ថ សត្ថកេន កេសេ ឆិន្ទិត្វា បព្វជិតោ នាម នត្ថិ, សព្វេ ឯហិភិក្ខុនោយេវ** *សូម្បីតែ ១ រូបដែលកោរសក់ដោយកាំបិតហើយបួសក៏មិនមាន សុទ្ធតែជាឯហិភិក្ខុទាំងអស់ ។ (បបញ្ចសូទនី អដ្ឋកថា មជ្ឈិមនិកាយ ទីឃនខសុត្តវណ្ណនា)*

## ២. ចតុរង្គសន្និបាតរបស់ព្រះសម្មាសម្ពុទ្ធពីបុរាណ

**១- សព្វេ ឯហិភិក្ខូ** *ភិក្ខុទាំងអស់សុទ្ធតែជាឯហិភិក្ខុ*

**២- សព្វេ ឥទ្ធិយា និព្វត្តបត្តចីវរា** *ភិក្ខុទាំងអស់សុទ្ធតែមានបាត្រនិងចីវរកើតឡើងដោយឫទ្ធិ*

**៣- សព្វេ អនាមន្តិតាវ អាគតា** *ភិក្ខុទាំងអស់សុទ្ធតែមកឥតនរណានិមន្ត*

**៤- ឥតិ តេ ច ខោ បន្នរសេ ឧបោសថទិវសេ** *មកក្នុងថ្ងៃឧបោសថ ១៥ កើត ។*

*( សុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ មហាវគ្គ មហាបទានសុត្ត សាវកសន្និបាតបរិច្ឆេទវណ្ណនា)*

*ដោយខេមរ អភិធម្មាវតារ*